# របាយការណ៍សិក្ខាសាលាប្រចាំឆ្នាំ
## របស់វេទិកាមនុស្សធម៌កម្ពុជា (CHF) និងវេទិកាឆ្លើយតបជំនួយមនុស្សធម៌ (HRF)
## ស្តីពីការរៀនសូត្រពីបទពិសោធន៍ និងផែនការសកម្មភាព

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦




## ១. សាវតារ

### *១.១ វេទិកាមនុស្សធម៌កម្ពុជា (CHF)*

វេទិកាមនុស្សធម៌កម្ពុជា (CHF) ក្រោមការឧបត្ថម្ភគាំទ្រជាថវិកាពី USAID/OFDA បានចាប់ផ្តើមអនុវត្តនៅខែឧសភា ឆ្នាំ២០១២។ គម្រោងនេះសម្របសម្រួលដោយមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយ អាស៊ី (ADPC) ដោយមានដៃគូរក្នុងប្រទេសជាមួយអង្គការ PADEK NCDM និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អនុវត្តកម្មវិធី «ពង្រឹងសមត្ថភាពការឆ្លើយតបគ្រោះអាសន្ននៃអង្គការមនុស្សធម៌នៅកម្ពុជា»។ គោលដៅរបស់គម្រោងគឺ ពង្រឹងការឆ្លើយតបមនុស្សធម៌ទៅនឹងគ្រោះមហន្តរាយនៅកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពជាអ្នកដឹកនាំដល់អង្គការខ្មែរ ដើម្បីភ្ជាប់ទំនាក់ទំនងការងារមនុស្សធម៌ឲ្យកាន់តែប្រសើរឡើង ការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល និងប្រឹក្សា យោបល់។

លទ្ធផលមួយក្នុងចំណោមលទ្ធផលទាំងឡាយរបស់គម្រោងគឺ ការបង្កើតជាវេទិកា CHF ដែលបានឯកភាពក្នុងសិក្ខាសាលាថ្នាក់ជាតិកាលពីខែកញ្ញា ឆ្នាំ២០១២។ ការបង្កើតជាវេទិកានេះ ក្នុងគោលបំណងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិល លើការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា និងដើម្បីបង្ហាញពីបញ្ហាគន្លឹះនានាដែលទាក់ទងការងារមនុស្សធម៌ ការត្រៀមបង្ការឆ្លើយតបគ្រោះមហន្តរាយ និងការគ្រប់គ្រងព័ត៌មាន។ រហូតដល់ខែកក្កដា ឆ្នាំ២០១៦នេះ វេទិកា CHF មានអង្គការខ្មែរជាសមាជិកចំនួន១១៥ ស្ថិតនៅ២១ក្នុងចំណោម២៥ រាជធានីខេត្ត។ ការទទួលបានជោគជ័យផ្សេងទៀតគឺ ការសម្របសម្រួលដោយបានបង្កើតទៅជាថ្នាក់តំបន់ដែលមានចំនួន៩ ហើយក្នុងមួយតំបន់មានខេត្ត២ ទៅ៣។

កាលពីឆ្នាំ២០១២-២០១៤ (ដំណាក់កាលទី១នៃគម្រោង) CHF បានផ្តល់វគ្គបណ្តុះបណ្តាលចំនួន១០វគ្គដល់សមាជិក និងដៃគូរពាក់ព័ន្ធ ដែលមានសិក្ខាកាមចូលរួមសរុប២៥៨នាក់ ក្នុងនោះស្ត្រី៨០នាក់ ស្តីពីការពង្រឹងសមត្ថភាពឆ្លើយតបគ្រោះអាសន្ន ដើម្បីផ្តល់ជាចំណេះដឹងមូលដ្ឋានស្តីពីការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ។ នៅឆ្នាំ២០១៤ -២០១៥ (ដំណាក់កាលទី២នៃគម្រោង) CHF បន្តផ្តល់វគ្គបណ្តុះបណ្តាលចំនួន៦វគ្គថ្មីថែមទៀត ដើម្បីពង្រឹងសមត្ថភាពដល់សមាជិកដែលមានសិក្ខាកាមចូលរួមសរុប១៤៧នាក់ ក្នុងនោះមានស្ត្រី៥២នាក់ ស្តីពីការត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ។ វគ្គនេះមានមេរៀនសំខាន់ចំនួន៣គឺៈ ១.ការរៀបចំផែនការត្រៀមបម្រុង

យថាហេតុ ២.កិច្ចសហប្រតិបត្តិការសម្របសម្រួលការងារមនុស្សធម៌ និង ៣.ការសិក្សាប៉ាន់ ប្រមាណពីតម្រូវការ និងការខូចខាតពេលមានគ្រោះមហន្តរាយ។ CHFក៏បានបង្កើតគេហទំព័រ www.chfcambodia.net ដើម្បីគាំទ្រដល់ ការបណ្តុះបណ្តាល ការបែងចែកព័ត៌មានពីការឆ្លើយតបគ្រោះអាសន្ន ការជូនដំណឹងព័ត៌មានព្រមានជាមុនពីមុខសញ្ញា គ្រោះថ្នាក់ និងព្រឹត្តិបត្តិព្យាករណ៍ទឹកជំនន់ជាដើម។

ក្រៅពីការបណ្តុះបណ្តាល CHF បានបង្កើតផែនការត្រៀមបម្រុងយថាហេតុសម្រាប់សមាជិក CHF ដោយ ផ្តោតលើការឆ្លើយតបគ្រោះទឹកជំនន់។ បង្កើតក្រុមសិក្សាប៉ាន់ប្រមាណគ្រោះមហន្តរាយ (EAT) និងសាកល្បងបង្កើត ក្រុមអ្នកស្ម័គ្រចិត្តមូលដ្ឋានឆ្លើយតបគ្រោះអាសន្ន (V2R) នៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ និងស្រុកចិត្របុរី ខេត្តក្រចេះ ដើម្បីចូលរួមសកម្មភាពត្រៀមបង្ការ និងឆ្លើយតបគ្រោះទឹកជំនន់ ម្យ៉ាងទៀតដើម្បីកាត់បន្ថយផលប៉ះពាល់ ពីគ្រោះមហន្តរាយ។

## *១.២ វេទិកាឆ្លើយតបជំនួយមនុស្សធម៌ (HRF)*

HRF ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១ ដើម្បីឆ្លើយតបនឹងកំនើនសេចក្តីត្រូវការសម្របសម្រួលជាមួយដៃគូរ អភិវឌ្ឍន៍ បង្ហាញពីតម្រូវការមនុស្សធម៌ បញ្ហាគ្រោះមហន្តរាយ ជាពិសេសគ្រោះទឹកជំនន់ និងរាំងស្ងួត។ គោលបំណង HRF គឺធានាកិច្ចសហការណ៍ និងការទំនាក់ទំនងរវាងអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និង អង្គការអន្តរជាតិ លើការងារត្រៀមបង្ការគ្រោះអាសន្ន និងឆ្លើយតបមនុស្សធម៌នៅកម្ពុជា។ HRF ធ្វើការទំនាក់ទំនង យ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ជាពិសេស NCDM ដើម្បីសម្របសម្រួលកិច្ចសហការ និងជួយគាំទ្រដល់ប្រជា ពលរដ្ឋដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយឲ្យមានប្រសិទ្ធិភាព។

បច្ចុប្បន្ន HRF ដឹកនាំដោយសហប្រធានមកពី WFP និង Action Aid គាំទ្រជាថវិកាដោយ USAID/OFDA។ មាន៣៥អង្គការចូលរួមមកពីៈ អង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការអន្តរជាតិ។ HRF សម្របសម្រួលលើផ្នែកសំខាន់ចំនួន៦គឺ ទឹកស្អាតនិងអនាម័យ សុខភាព សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការការពារ ការអប់រំ និងជម្រក។

*ការក្តេង់ផ្តោតរបស់ HRF*

**សហការក្នុងការត្រៀមបម្រុង**

- ធ្វើឲ្យប្រសើរឡើងនូវផែនការត្រៀមបម្រុងយថាហេតុជារួម និងតាមផ្នែក រួមមានសកម្មភាពត្រៀមបង្ការកម្រិត អប្បបរិមា
- ឯកភាព និងបណ្តុះបណ្តាលពីឧបករណ៍វាយតម្លៃបទដ្ឋានរួម
- ធ្វើឲ្យប្រសើរឡើងនូវការចែកចាយពត៌មាន និងវិធីសាស្ត្រគ្រប់គ្រងពត៌មានស្តីពីការផ្តល់ពត៌មានជាមុន និង ផលប៉ះពាល់គ្រោះមហន្តរាយ
- ពង្រឹងសមត្ថភាពបុគ្គលិកពីការត្រៀមបង្ការ និងឆ្លើយតប
- លើកទឹកចិត្តក្នុងការដាក់បញ្ចូលការកាត់បណ្តយហានិភ័យនៃគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍

**សហការក្នុងការឆ្លើយតប**

- ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវបញ្ជីជនបង្គោលឆ្លើយតប
- ប្រជុំជាទៀងទាត់ដើម្បីធានាការត្រៀមបង្ការ និងសហការក្នុងការឆ្លើយតប
- រៀបចំ/ចែកចាយទិន្នន័យដើម្បីជួយដល់ការកំណត់ពីតម្រូវការជាមុន យល់ច្បាស់ពីសេណារីយ៉ូហានិភ័យ និង ជម្រាបពីទីកន្លែង

**ការគៀងគរធនធាន**

- គៀងគរធនធានឲ្យបានទាន់ពេលវេលាឆ្លើយតបនិងតម្រូវការ
- បណ្តុះបណ្តាលបុគ្គលិករួចជាស្រេចដើម្បីចុះធ្វើការវាយតម្លៃ
- វិភាគពីតម្រូវការ និងផែនការឆ្លើយតបដើម្បីរំលឹកដល់ការរៀបចំជាយុទ្ធសាស្រ្ត
- ចែកចាតពត៌មានដោយលើកទឹកចិត្តក្នុងការសហការគៀងគរធនធាន
- លើកឡើងការការពារ និងផ្សព្វផ្សាយក្នុងបរិបទកម្ពុជា

សិក្ខាសាលាប្រចាំឆ្នាំនេះមានរយៈពេល១ថ្ងៃ ដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃកិច្ចសហការ រវាងអន្តរភ្នាក់ងារលើការបណ្តុះបណ្តាល និងលំហាត់សមយុទ្ធលើគុ រួមគ្នារវាង HRF និង CHF។ ព្រមទាំងបង្ហាញជូនពីលទ្ធផលនានាសម្រេចបាន ផែនការសម្រាប់រយៈពេល២ឆ្នាំខាងមុខ ពិភាក្សានិងកែសម្រួលនិតិវិធីបទដ្ឋានប្រតិបត្តិ CHF និង បោះឆ្នោតជ្រើសរើសគណៈកម្មាធិការដឹកនាំវេទិកា CHF អាណត្តិថ្មី

## ២. សមាសភាពអ្នកចូលរួម (១០៧នាក់)

- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២នាក់
- តំណាង ADPC, Bangkok ២នាក់
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១នាក់
- លេខាធិការដ្ឋាន CHF ៣នាក់
- សមាជិក CHF ទាំងអស់ ៩០នាក់
- តំណាង HRF ៩នាក់

## ៣. វិធីសាស្រ្ត

វិធីសាស្រ្តជាច្រើនត្រូវបានប្រើរួមមាន៖ បទបង្ហាញ កិច្ចពិភាក្សាក្រុមធំ ក្រុមពិភាក្សា ការបំផុសគំនិត សំនួរ-ចម្លើយ ការឯកភាពតាមការលើកដៃ និងបោះឆ្នោតជាដើម ត្រូវបានប្រើប្រាស់ក្នុងពេលសិក្ខាសាលា ដើម្បីឲ្យអ្នកចូលរួមទាំងអស់បានចូលរួមពេញលេញ និងឯកភាពគ្នា។

## ៤. ពិធីបើកសិក្ខាសាលា



- មតិស្វាគមន៍ដោយបណ្ឌិត Jingjai Hanchanlash នាយក ADPC

ជាកិច្ចចាប់ផ្តើម បណ្ឌិត Jingjai Hanchanlash លោកបានមានមតិស្វាគមន៍ ចំពោះគណៈអធិបតី ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំង HRF និងសមាជិក CHF ទាំងអស់។ លោកមានប្រសាសន៍ថា លោកមានសេចក្តីរីករាយដែលបានចូលរួមជាគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលា CHF និង HRF ប្រចាំឆ្នាំ ស្តីពីការរៀនសូត្រពីបទពិសោធន៍ និងផែនការសកម្មភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិត ញឹម វណ្ណដា។

លោកក៏បានសង្ខេបពីជំនាញ និងបទពិសោធន៍របស់ ADPC ជាង៣០ឆ្នាំកន្លងមក លើការងារគ្រប់គ្រងគ្រោះមហន្តរាយនៅអាស៊ី និងប៉ាស៊ីហ្វិក។ ADPC បានចូលរួមសកម្មភាពយ៉ាងសកម្មក្នុងការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅកម្ពុជាតាំងពីឆ្នាំ១៩៩០ ជាមួយ NCDM និងក្រសួងមួយចំនួនដូចជា MoP, MOWRAM, MoEYS និង MoH ជាដើម។ នៅឆ្នាំ១៩៩៧ ADPC បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ NCDM CRC និងអង្គការដៃគូផ្សេងទៀតក្នុងការអនុវត្តគម្រោងការកសាងសមត្ថភាព។ នៅឆ្នាំ២០០៣ ADPC ក្នុងភាពជាដៃគូរជាមួយ MRCs និង CNMC បានអនុវត្តគម្រោងពង្រឹងការគ្រប់គ្រងគ្រោះទឹកជំនន់។ ADPC ក៏បានផ្តល់ជំនួយបច្ចេកទេសដល់ NCDM និង MOWRAM ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យនៃគ្រោះទឹកជំនន់ និងរាំងស្ងួត តាមរយៈយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅថ្នាក់សហគមន៍។ ADPC បានគាំទ្រ NCDM ក្នុងការវាយតម្លៃពីតម្រូវការក្រោយគ្រោះមហន្តរាយដោយព្យុះកេតសាណា ថវិកាពី World Bank ជាដើម។

នៅឆ្នាំ២០១២ វេទិកាមនុស្សធម៌កម្ពុជា (CHF) ត្រូវបានបង្កើតឡើង ដែលសម្របសម្រួលដោយ ADPC ក្រោមការឧបត្ថម្ភគាំទ្រជាថវិកាពី USAID/OFDA ដោយមានដៃគូរក្នុងប្រទេសជាមួយ អង្គការ PADEK NCDM និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានអនុវត្តកម្មវិធី «ពង្រឹងសមត្ថភាពការឆ្លើយតបគ្រោះអាសន្ននៃអង្គការមនុស្សធម៌នៅកម្ពុជា»។ គោលដៅរបស់គម្រោងគឺ ពង្រឹងការឆ្លើយតបមនុស្សធម៌ ទៅនឹងគ្រោះ មហន្តរាយនៅកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពជាអ្នកដឹកនាំដល់អង្គការខ្មែរ ដើម្បីភ្ជាប់ទំនាក់ទំនងការងារមនុស្សធម៌ ឲ្យកាន់តែប្រសើរឡើង ការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល និងប្រឹក្សាយោបល់។

លទ្ធផលសម្រេចបានទាំងនេះ គឺជាការចូលរួមចំណែកពី ADPC លើវិស័យការត្រៀមបង្ការគ្រោះមហន្តរាយ និងឆ្លើយតបមនុស្សធម៌ ដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពឆ្លើយតបគ្រោះមហន្តរាយ និងបម្រែបម្រួលអាកាសធាតុ។

- មតិស្វាគមន៍ដោយលោក GianPietro BORDIGNON សហប្រធាន HRF និងជាប្រធាន WFP ប្រចាំប្រទេស

លោកបានមានប្រសាសន៍ថា លោកសូមថ្លែងអំណរគុណដល់ CHF ដែលបានអញ្ជើញរូបលោកចូលរួមជាគណៈអធិបតី ក្នុងភាពជាដៃគូររវាង HRF និង CHF ដែលបានធ្វើការសហការណ៍គ្នាតាំងពីឆ្នាំ២០១១មក ក្រោមការឧបត្ថម្ភគាំទ្រជាថវិកាពី USAID។ ក្នុងរយៈពេល០៧ខែចុងក្រោយនេះ HRF និង CHF សម្រេចបាននូវការអនុវត្តសកម្មភាពរួមគ្នាជាច្រើន ដូចជាមានតំណាង CHF ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគ្រោះអាសន្ន និងលំហាត់សមយុទ្ធលើតុ នៅខេត្តកំពង់ធំ បាត់ដំបង និងភ្នំពេញ ជាដើម។

ក្នុងនាម HRF សូមវាយតម្លៃខ្ពស់ចំពោះ NCDM និង CHF ដែលតែងតែជួយគាំទ្រ និងផ្តល់កិច្ចសហការណ៍លើការងារគ្រោះមហន្តរាយប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីការងារវិមជ្ឈការរហូតដល់ថ្នាក់មូលដ្ឋាន ដែលដឹកនាំដោយ NCDM ដើម្បីជួយជម្រុញដំណើរការវិមជ្ឈការ ដែលជាដំណើការមួយដ៏ធំធេង ជាជំហានៗដើម្បីជួយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមពីគ្រោះមហន្តរាយ ដូចជាគ្រោះទឹកជំនន់ និងរាំងស្ងួត ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។ ដូច្នេះសកម្មភាពទាំងនេះក៏បានចូលរួមចំណែកក្នុងការស្តារឡើងវិញ និងកាត់បណ្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេស។

WFP បានធ្វើការទៅតាមផែនការគោលនយោបាយរបស់រដ្ឋាភិបាល ហើយក៏មានអាណត្តិលើការងារគ្រោះមហន្តរាយ ដើម្បីសម្រេចឲ្យបាននូវគោលដៅក្នុងការកាត់បណ្ថយ ហានិភ័យនៃគ្រោះមហន្តរាយ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ បើពិនិត្យឡើងវិញនូវសកម្មភាពអាទិភាពនានា និងអង្គការដៃគូរដែលបានចូលរួមការងារកាត់បណ្ថយហានិភ័យនៃគ្រោះមហន្តរាយ WFP សូមលើកទឹកចិត្តបន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។

CHF មានរចនាសម្ព័ន្ធគ្រប់គ្រងទាំងថ្នាក់ជាតិ តំបន់ និងខេត្ត ដែលមានសមាជិកជាច្រើន វត្តមានរបស់ CHF ពិតជាមានសារៈសំខាន់ណាស់នៅកម្ពុជា ក៏ដូចជាដៃគូរផ្សេងទៀតរួមមាន UN, iNGOs, CRC ដែលអាចជាអ្នកផ្តល់ជំនួយគាំទ្រក្នុងការឆ្លើយតប ដើម្បីត្រៀមបង្ការកាត់បន្ថយហានិភ័យ។

- សន្ទរកថាបើកអង្គសិក្ខាសាលាដោយ **ឯកឧត្តម បណ្ឌិត ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី អនុប្រធានប្រចាំការ និងជាប្រធានគណៈកម្មាធិការប្រត្តិបត្តិ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ឯកឧត្តមមានប្រសាសន៍ថា ឯកឧត្តមមានសេចក្តីរីករាយ ដែលបានមកចូលរួមក្នុងពិធីបើកអង្គសិក្ខាសាលាប្រចាំឆ្នាំរបស់ CHF ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការទំនាក់ទំនង និងកិច្ចសហការកន្លងមកក្នុងការត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ ដើម្បីរៀនសូត្រពីបទពិសោធន៍ និងផែនការសកម្មភាពបន្ត។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ការពង្រឹងចំណេះដឹង បទពិសោធន៍ និងចំណេះធ្វើពីកិច្ចសហប្រតិបត្តិការ និងទទួលបានជោគជ័យ។

ឯកឧត្តម បានលើកឡើងថា ADPC បានជួយគាំទ្រ និងសហការជាមួយ NCDM លើការងារគ្រោះមហន្តរាយជាច្រើន រួមទាំងការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រី។ ហើយឯកឧត្តម ក៏មានសេចក្តីរីករាយដែល USAID បន្តជួយឧបត្ថម្ភគាំទ្រដល់ CHF ក្នុងការបន្តពង្រឹងសមត្ថភាពដល់អង្គការខ្មែរ លើការងារជំនួយមនុស្សធម៌ដែលនេះជាផ្នែកមួយក្នុងការកសាងធនធានមនុស្ស ដើម្បីជួយកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋកម្ពុជា។ គ្រោះមហន្តរាយតែងតែកើតមានឡើងជាបន្តបន្ទាប់ មិនថានៅប្រទេសកម្ពុជា ឬនៅប្រទេសដ៏ទៃទៀតលើពិភពលោក ភាពរងគ្រោះដោយគ្រោះមហន្តរាយ ក៏កើតមានជាបន្តបន្ទាប់ដែរ។ ដូច្នេះដើម្បីកាត់បន្ថយភាពងាយរងគ្រោះបានមានតែការបង្កើនសមត្ថភាពក្នុងការត្រៀមបង្ការ និងឆ្លើយតបនៅគ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ។

ដូច្នេះឃើញថាអ្វីដែល CHF បានធ្វើកន្លងមក ពិតជាស្របទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការពង្រឹង និងពង្រីកធនធានមនុស្ស ផ្នែកការងារត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ និងក៏ស្របគ្នាជាមួយច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ដែលទើបបង្កើតឡើងនាពេលថ្មីៗនេះ។ កន្លងមកវត្តមានរបស់អង្គការខ្មែរ មានតិចតួចដែលមានសមត្ថភាពចូលរួម ក្នុងការងារផ្តល់ជំនួយមនុស្សធម៌ឬសង្គ្រោះបន្ទាន់ ប៉ុន្តែចាប់ពីពេលនេះតទៅ ខ្ញុំជឿជាក់ថាអង្គការខ្មែរ ជាពិសេសអង្គការដែលជាសមាជិកCHF នឹងមានសមត្ថភាពចូលរួមសម្របសម្រួលការងារគ្រោះមហន្តរាយជាមួយ HRF និងអង្គការដៃគូអន្តរជាតិផ្សេងៗទៀត ជាពិសេសជាមួយ NCDM។

ឯកឧត្តម ក៏បានជម្រាបជូនថា ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ក៏ត្រូវបានចូលជាធរមានក្រោយពីព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខា ដែលនេះក៏ជាចំណែកមួយ នៃភាពជឿនលឿនផ្នែកការងារគ្រប់គ្រងគ្រោះមហន្តរាយ និងជាជំនួយមួយដ៏ចាំបាច់សម្រាប់អនុវត្តន៍ការងារដែលទាក់ទងជាមួយ និងការងារគ្រប់គ្រងគ្រោះមហន្តរាយ។

## ៥. លទ្ធផល និងដំណើរការសិក្ខាសាលា

- បទបង្ហាញពីលទ្ធផលសម្រេចបានរបស់ HRF ដោយលោក Ammar KAWASH មន្ត្រី WFP

លោកបានបង្ហាញពីអ្វីទៅជាវេទិកាឆ្លើយតបជំនួយមនុស្សធម៌(HRF) ដែលរួមមានរចនាសម្ព័ន្ធ និងអ្នកចូលរួមការបែងចែកផ្នែកទាំង៦ក្នុងការសម្របសម្រួល និងការធ្វើផែនការរួមគ្នារវាង CHF និង HRF ដោយផ្តោតលើការត្រៀម

បង្ការ និងឆ្លើយតប ហើយកំណត់ពីសកម្មភាពអាទិភាពដែលត្រូវសហការណ៍គ្នាក្នុងឆ្នាំ២០១៦-២០១៧ រួមមាន ១. រៀបចំកំណត់ថា តើអង្គការណាធ្វើអ្វី និងនៅកន្លែងណា (3ws) ២. រៀបចំផែនការត្រៀមបម្រុងយថាហេតុរួមគ្នា ៣. វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគ្រោះអាសន្នរួមគ្នា ៤. រៀបចំលំហាត់សមយុទ្ធលើតុរួមគ្នា។

លទ្ធផលសម្រេចបានពីការធ្វើផែនការរួមគ្នា រួមមាន៖ ១. វគ្គបណ្តុះបណ្តាលស្តីពី ការវាយតម្លៃគ្រោះអាសន្ន ២វគ្គ នៅខេត្តកំពង់ធំ និងបាត់ដំបង ដែលមានសមាជិក CHF ចូលរួមសរុប១៥នាក់ ២. ការរៀបចំលំហាត់សមយុទ្ធលើតុ នៅខេត្តកំពង់ធំ បាត់ដំបង និងភ្នំពេញ មានសមាជិក CHF ចូលរួមសរុប១៥នាក់។ ដោយឡែកសកម្មភាពដែលត្រូវធ្វើបន្តរួមមាន៖ ១.ការរៀបចំ 3ws និង ២.រៀបចំផែនការត្រៀមបម្រុងយថាហេតុរួមគ្នា។

បន្ទាប់ពីបទបង្ហាញ មានសំនួរ ចម្លើយ និសំណូមពរជាច្រើនដូចជា ១. គួរកែសម្រួលឧបករណ៍វាយតម្លៃ (KI និង FGD) ដោយវែងពេក និងសំនួរខ្លះលំបាកយល់ ២. វគ្គបណ្តុះបណ្តាល សូមបន្តបង្រៀនជាភាសាខ្មែរ និងឯកសារមេរៀនជាភាសាខ្មែរ ៣. សូមផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ការវាយតម្លៃគ្រោះអាសន្ន បន្ថែមទៀត ជាពិសេសដល់ថ្នាក់ក្រោមជាតិ។

បន្ទាប់មកអ្នកចូលរួមទាំងអស់បានបែងចែកជា៤ក្រុមពិភាក្សា៖ ក្រុមទី១. ពិភាក្សាពីវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) ស្តីពីការវាយតម្លៃគ្រោះអាសន្ន ដោយ HRF សម្របសម្រួលដោយ លោក សំ សុវណ្ណ ប្រធានអង្គការ NRD ក្រុមទី២. ពិភាក្សាពីលំហាត់សមយុទ្ធលើតុ (CamREx) នៅខេត្តកំពង់ធំ សម្របសម្រួលដោយ លោក ប៊ុន រិទ្ធី ប្រធានអង្គការ DND ក្រុមទី៣. ពិភាក្សាពីលំហាត់សមយុទ្ធលើតុ នៅខេត្តបាត់ដំបង សម្របសម្រួលដោយ លោក នៅ សុទ្ធា អង្គការ PADEK និងក្រុមទី៤. ពិភាក្សាពីលំហាត់សមយុទ្ធលើតុ នៅភ្នំពេញ សម្របសម្រួលដោយ លោក អ៊ឹម ណារិទ្ធ អង្គការ PADEK។ ក្រុមទាំង៤ ពិភាក្សាពី ១. ស្វែងរកចំណុចខ្លាំងពីការរៀបចំ (TOT/ CamREx) ២. ស្វែងរកចំណុចខ្វះខាតពីការរៀបចំ (TOT/ CamREx) និង ៣. អនុសាសន៍ តើគួរធ្វើយ៉ាងដូចម្តេចដើម្បីឲ្យប្រសើរឡើង។

❖ លទ្ធផលក្រុមពិភាក្សាលំហាត់សមយុទ្ធលើតុ (ខេត្តកំពង់ធំ បាត់ដំបង និងភ្នំពេញ)

| ចំណុចខ្លាំង | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|
| - មានព័ត៌មានមកពីច្រើនប្រភព និងមានភាគីពាក់ព័ន្ធចូលរួមច្រើន ទាំងស្ថាប័ណរដ្ឋាភិបាល អង្គការជាតិ និងអង្គការអន្តរជាតិ<br>- មានកិច្ចសហការណ៍គ្នាល្អ<br>- មានសេណារីយ៉ូច្បាស់លាស់<br>- មានការបែងចែកក្រុមពិភាក្សាតាមកម្រិត ជាតិ ខេត្ត ស្រុក ឃុំ<br>- កិច្ចសហការជាមួយស្ថាប័ណពាក់ព័ន្ធពេលមានគ្រោះមហន្តរាយ<br>- មានយន្តការឆ្លើយតប<br>- មានការចែករំលែកព័ត៌មាន<br>- មានរចនាសម្ព័ន្ធឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - ព័ត៌មានមិនច្បាស់លាស់តែ១ ប្រើគ្រប់កម្រិតទាំងថ្នាក់ជាតិ និងខេត្ត<br>- កំរិតនៃការឆ្លើយតបមិនច្បាស់ ជាតិ ខេត្ត ឬស្រុក?<br>- ពេលវេលាសម្រាប់លំហាត់ខ្លី<br>- ការបែងចែកសមាជិកតាមក្រុម ខ្លះមានចំនួនច្រើនពេក (ជាង៣០នាក់) អ្នកសម្របសម្រួល តែ១នាក់ លំបាកគ្រប់គ្រង<br>- សំនួរច្រើនពេក<br>- ក្រដាសព័ត៌មានតែ១ ឬ២សន្លឹក មើល១ក្រុមធំ<br>- សំនួរច្រើនពេក<br>- សមាសភាពអ្នកចូលរួម មិនត្រូវជំនាញ<br>- សេណារីយូពិភាក្សាមិនច្បាស់លាស់<br>- អ្នកចូលរួមខ្វះឆន្ទះ<br>- ជំនាញអ្នកសម្របសម្រួល មិនទាន់ច្បាស់លាស់ | - គួរមានសេណារីយូច្បាស់លាស់ តើទឹកជំនន់ ឬរាំងស្ងួត<br>- គួរធ្វើឲ្យបានច្រើនខេត្តជាងនេះ<br>- ជ្រើសរើសអ្នកចូលរួមឲ្យចំជំនាញ ធ្វើការផ្នែកគ្រោះមហន្តរាយ<br>- ការចូលរួមពី NGOs គួរមានច្រើន<br>- ប្រធានបទ និងសេណារីយូ គួរមានភាពច្បាស់លាស់<br>- អ្នកសម្របសម្រួលក្រុមរួម និងក្រុមតូច គួរមានជំនាញ និងបទពិសោធន៍<br>- ការបែងចែកក្រុមពិភាក្សា គួរឲ្យបានសមស្រប មិនគួរធំពេក<br>- ឧបករណ៍សម្ភាសន៍វែង ចំណាយពេលច្រើន គួរកែសម្រួល |

❖ លទ្ធផលក្រុមពិភាក្សា វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តកំពង់ធំ បាត់ដំបង)

| ចំណុចខ្លាំង | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|
| - មានគោលបំណងច្បាស់លាស់<br>- បែងចែកពេលវេលាបានច្បាស់លាស់ទៅតាមមេរៀន<br>- មានការអនុវត្តជាក់ស្តែងតាមមេរៀន<br>- អ្នកសម្របសម្រួលបកស្រាយបានល្អ<br>- សិក្ខាកាមអាចបណ្តុះបណ្តាលបន្តបាន<br>- បានយល់ពីដំណើការនៃការវាយតម្លៃ<br>- មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ NCDM CHF HRF | - ការបកប្រែឯកសារ និងអ្នកបកប្រែពេលបង្រៀន គួរមានជំនាញ<br>- ឯកសារបង្រៀន និង Power Point រៀបចំមិនទាន់រួច ពេលបង្រៀន<br>- បន្ទប់រៀន មានសសរបាំង និងលំបាកមើល<br>- អ្នកបកប្រែ ដើរតួនាទីជាគ្រូសម្របសម្រួល | - អ្នកបកប្រែគួរមានចំណេះដឹងការងារគ្រោះមហន្តរាយ<br>- អ្នកបកប្រែមិនគួរឆ្លើយសំនួរ ជំនួសគ្រូសម្របសម្រួល<br>- គួររៀបចំឯកសារឲ្យបានរួចរាល់មុនពេលបង្រៀន<br>- ការបង្រៀនគួរធ្វើតាមលំដាប់លំដោយមេរៀន នៃកម្មវិធី |

- របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការអនុវត្តគម្រោង CHF និងផែនការសកម្មភាព CHF សម្រាប់២ឆ្នាំខាងមុខ ដោយ លោក កឿក សុខ
  1. ចំនួនសមាជិក CHF រហូតដល់ពេលនេះមានចំនួន ១១៥ អង្គការ
  2. កិច្ចប្រជុំរួមរវាង CHF និង HRF ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥
  3. CHF ៧នាក់ និងសាស្ត្រាចារ្យ១នាក់ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទៅរៀនវគ្គ DMC នៅប្រទេសថៃ
  4. វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគ្រោះអាសន្ន នៅខេត្តកំពង់ធំ និងបាត់ដំបង ខែមិថុនា ២០១៦ CHF ១៥នាក់ បានចូលរួម
  5. ផែនការត្រៀមបម្រុងយថាភាពបានធ្វើបច្ចុប្បន្នភាពនិងប្រគល់ជូន HRF ដើម្បីដាក់បញ្ចូលគ្នា
  6. លំហាត់សមយុទ្ធនៅខេត្តកំពង់ធំ បាត់ដំបង និងភ្នំពេញ CHF ចូលរួម ១៥នាក់
  7. ចូលរួមសិក្សាប៉ាន់ប្រមាណគ្រោះរាំងស្ងួតចំនួន១០ខេត្ត ដោយ១២អង្គការសមាជិក CHF
  8. ប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការដោទៀងទាត់
  9. សិក្ខាសាលាប្រកាសអំពីវគ្គ DM ជាមួយ RUPP
  10. ការប្រជុំប្រចាំត្រីមាសតាមតំបន់ (៨តំបន់) លើកលែងតំបន់៩ ខេត្ត កោះកុង និងព្រះសីហនុ
  11. ទទួលបានគម្រោងថ្មីពី USAID តាមរយៈ ADPC រយៈពេល២ឆ្នាំ (១កុម្ភៈ ២០១៦-៣១ មករា ២០១៨)

- ផែនការ២ឆ្នាំ ២០១៦ ដល់២០១៨ របស់ CHF
  1. រកសមាជិកឲ្យបានយ៉ាងតិច ១៤៥អង្គការ
  2. កិច្ចប្រជុំប្រចាំឆ្នាំចំនួន២លើក
  3. កិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការ និង Zone
  4. វគ្គបណ្តុះបណ្តាលស្តីពី វិស័យទំនាក់ទំនង និងការប្រើប្រាស់គេហទំព័រ (១វគ្គ)
  5. វគ្គបណ្តុះបណ្តាល TOT នៅខេត្តកំពង់ធំ និងបាត់ដំបង ខែមិថុនា ២០១៦ CHF ១៥ នាក់
  6. រៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលចំនួន៧
  7. ផ្តល់វគ្គ TOT ថ្នាក់ខេត្តសម្រាប់គ្រូ ៥០នាក់ (២វគ្គ)
  8. ផ្តល់វគ្គបណ្តុះបណ្តាលថ្នាក់ស្រុក សម្រាប់ ៧៥នាក់ (៣វគ្គ)
  9. ផែនការត្រៀមបម្រុងយថាភាពបានធ្វើបច្ចុប្បន្នភាពនិងប្រគល់ជូន HRF ដើម្បីដាក់បញ្ចូលគ្នា

10. លំហាត់សមយុទ្ធនៅខេត្តកំពង់ធំ បាត់ដំបង និងភ្នំពេញ CHF ចូលរួម ១៥នាក់
11. ការងារជាមួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (សិក្ខាសាលា២ និងបញ្ជូនសាស្ត្រាចារ្យ៣នាក់ទៅរៀន)
12. ផ្តល់វគ្គរំឭកឡើងវិញសម្រាប់ក្រុមប៉ាន់ប្រមាណ
13. បង្កើតបន្ថែមនូវក្រុមអ្នកស្ម័គ្រចិត្តឆ្លើយតបថ្នាក់សហគមន៍ចំនួន២ ព្រមទាំងផ្តល់នូវវគ្គបណ្តុះបណ្តាល និងការងារយុទ្ធនាការត្រៀមបង្ការទឹកជំនន់។

- ពិភាក្សាកែសម្រួលនិតិវិធីបទដ្ឋានប្រតិបត្តិ CHF ដោយ លោក ជិន វិបុល

លោក បានសម្របសម្រួលជាមួយសមាជិកទាំងអស់ ជាលទ្ធផលបានឯកភាពដូចខាងក្រោម៖

<u>គណៈកម្មាធិការដឹកនាំវេទិកា CHF</u>

- ❖ ឯកភាពកែសម្រួលអាណត្តិរបស់គណៈកម្មាធិការដឹកនាំវេទិកា មានរយៈពេល៣ឆ្នាំក្នុង១អាណត្តិ ចាប់ពីអាណត្តិទី៣ ឆ្នាំ២០១៦ នេះតទៅ ដែលកន្លងមកមានតែ២ឆ្នាំ។ ក្នុងករណីចាំបាច់ សមាជិកគណៈកម្មាធិការដឹកនាំវេទិកា អាចស្នើសុំលាឈប់មុនអាណត្តិបាន
- ❖ ឯកភាពអាណត្តិរបស់សមាជិកគណៈកម្មាធិការនីមួយៗ មិនអាចឈរឈ្មោះបានលើសពី ០២(ពីរ) អណត្តិបានឡើយ (ប៉ុន្តែករណីពិសេសសម្រាប់អាណត្តិទី៣ ឆ្នាំ២០១៦នេះ សមាជិកគណៈកម្មាធិការដែលដល់២អណត្តិ អាចឈរឈ្មោះបន្តបាន១អណត្តិទៀត)។ ក្រោយពីបញ្ចប់ ០២ អណត្តិ សមាជិកគណៈកម្មាធិការត្រូវមិនឈរឈ្មោះ ០១អណត្តិសិន ហើយបន្ទាប់មកបើសិនជាចង់ឈរឈ្មោះបន្ត គឺអាចឈរឈ្មោះបន្តទៀតបាន។

<u>អ្នកសម្របសម្រួល CHF ថ្នាក់តំបន់ និងថ្នាក់ខេត្ត</u>

- ❖ ឯកភាពកែសម្រួលអាណត្តិរបស់អ្នកសម្របសម្រួលថ្នាក់តំបន់ មានរយៈពេល៣ឆ្នាំក្នុង១អាណត្តិ ចាប់ពីអាណត្តិទី៣ ឆ្នាំ២០១៦ នេះតទៅ ដែលកន្លងមកមានតែ២ឆ្នាំ
- ❖ ឯកភាពអ្នកសម្របសម្រួលថ្នាក់តំបន់ និងអ្នកសម្របសម្រួលថ្នាក់ខេត្ត អាចស្នើសុំឈប់មុនអាណត្តិបានដោយសរសេរលិខិតស្នើសុំមកលេខាធិការដ្ឋាន ហើយលេខាធិការដ្ឋាន និងសម្របសម្រួលជ្រើសរើសអ្នកសម្របសម្រួលថ្មី នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសថ្នាក់តំបន់ ឬប្រចាំឆ្នាំ ដោយមានការចូលរួមពីតំណាងសមាជិកគណៈកម្មាធិការដឹកនាំវេទិកា១នាក់។

- ជ្រើសរើសអ្នកសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដែលបានសុំលាឈប់ ឬមិនទាន់មាន

<u>អ្នកសម្របសម្រួល CHF ថ្នាក់តំបន់</u>

- ❖ លោក ហ៊ី ស្រស់ ប្រធានអង្គការ DARE ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួលតំបន់ IV ខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន ជំនួសលោក ហ៊ាន សុវណ្ណដារ៉ា មកពីអង្គការ TDSP ដែលសុំលាឈប់។
- ❖ លោក ផៃ ធួក ប្រធានអង្គការ CCD ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF តំបន់ VII ខេត្តតាកែវ កំពត និងកែប ជំនួសលោក អ៊ុម សំអឿន មកពីអង្គការ RACHANA ដែលសុំលាឈប់

<u>អ្នកសម្របសម្រួល CHF ថ្នាក់ខេត្ត</u>

- ❖ លោក ចាន់ ទីណូ ប្រធានអង្គការ PNKS ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF ខេត្តព្រៃវែង ជំនួសលោក ឯម សុខា មកពីអង្គការ PADEK ដែលសុំលាឈប់

- ❖ លោកស្រី ព្រុំ បុប្ផា ប្រធានអង្គការ RAO ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF ខេត្តស្វាយរៀង ជំនួសលោក សួន សារ៉ាយ មកពីអង្គការ ADIFE ដែលសុំលាឈប់
- ❖ លោក គង់ សេដ្ឋ ប្រធានអង្គការ CYD ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF ខេត្តកំពង់ឆ្នាំង ជំនួសលោកស្រី សរ សាធ មកពីអង្គការ AEC ដែលសុំលាឈប់
- ❖ លោក អឿន រតនា ប្រធានអង្គការ CIDO ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF ខេត្តឧត្តរមានជ័យ ជំនួសលោកស្រី សាក់ មុំ មកពីអង្គការ PADEK ដែលសុំលាឈប់
- ❖ លោក ភូ តេង ប្រធានអង្គការ CWDCC ត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួល CHF ខេត្តកំពត។

## - របាយការណ៍ប្រមូលប្រាក់សមាជិកភាព CHF

រហូតមកដល់ពេលនេះ មានអង្គការខ្មែរដែលជាសមាជិក CHF ចំនួន ៣៩/១១៦ បានបង់ប្រាក់សមាជិក គិតជាថវិកាចំនួន ១៧៤០ដុល្លា។

## - ពិភាក្សាលក្ខណៈវិនិច្ឆ័យជ្រើសរើសគណៈកម្មាធិការដឹកនាំវេទិកាថ្មី

សមាជិកទាំងអស់បានឯកភាពលក្ខណៈវិនិច្ឆ័យជ្រើសរើសដូចខាងក្រោម៖

- ❖ អង្គការដែលជាសមាជិក CHF
- ❖ បានបង់ប្រាក់សមាជិកភាព CHF គ្រប់គ្រាន់ ទៀងទាត់ និងទាន់ពេលវេលា
- ❖ ប្រធានអង្គការជាស្ត្រី ត្រូវបានផ្តល់អាទិភាព (ព្រោះក្នុងគោលការណ៍បានចែងថាសមាសភាព សមាជិក គណៈកម្មាធិការយ៉ាងហោចណាស់២នាក់ ដែលជាស្ត្រីក្នុងចំណោមសមាជិកទាំង៥)
- ❖ សកម្មជាមួយការងារវេទិកា និងមានការប្តេជ្ញាចិត្តខ្ពស់ ជួយជ្រោមជ្រែងលើកស្ទួយ CHF
- ❖ យល់ព្រមធ្វើដំណើរទៅចូលរួមប្រជុំ សិក្ខាសាលាទាំងក្នុង និងក្រៅប្រទេស ក្នុងនាមជាតំណាង CHF
- ❖ ក្នុងករណីជាប្រធានគណៈកម្មាធិកា មេដឹកនាំអង្គការ ត្រូវមានសមត្ថភាពអាចនិយាយភាសាអង់គ្លេសក្នុង ការទំនាក់ទំនង និងមានចំណេះដឹងការងារគ្រោះមហន្តរាយ។

## - ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការដឹកនាំវេទិកា CHF អាណត្តិទី៣

- ❖ បេក្ខជនឈរឈ្មោះជាគណៈកម្មាធិការ (១០រូប)



| | | | |
|---|---|---|---|
| 1. | លោក កែប ក័ណ្ណារូ | PADEK | ភ្នំពេញ |
| 2. | លោក ហ៊ឹម សារឿន | SORF | ពោធិ៍សាត់ |
| 3. | លោក ហ៊ុម សាគន្ធ | CCD-Kratie | ក្រចេះ |

4. លោក ហ៊ាន សុវណ្ណដារ៉ា TDSP បន្ទាយមានជ័យ
5. លោក ឡេង ប៊ុនហុង SACRED ព្រៃវែង
6. លោកស្រី ព្រំ បុប្ផា RAO ស្វាយរៀង
7. លោក ដា សារិទ្ធ WOMEN ភ្នំពេញ
8. លោកស្រី រស់ ធវីវណ្ណ VSG បាត់ដំបង
9. លោក យឹម ប៊ុនថេង COFAP កំពង់ធំ
10. លោកស្រី យស ធី KWWA ក្រចេះ

❖ លទ្ធផលនៃការបោះឆ្នោត

| អង្គការ | PADEK | SORF | CCD-Kratie | TDSP | SACRED | RAO | WOMEN | VSG | COFAP | KWWA |
|---|---|---|---|---|---|---|---|---|---|---|
| ពិន្ទុសរុប | 685 | 419 | 417 | 369 | 379 | 420 | 387 | 439 | 338 | 458 |
| ចំណាត់ថ្នាក់ | 1 | 5 | 6 | 9 | 8 | 4 | 7 | 3 | 10 | 2 |

❖ សមាជិកគណៈកម្មាធិការដឹកនាំវេទិកា CHF អាណត្តិទី៣ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ២០១៦

1. លោក កែប កណ្ណារូ PADEK ភ្នំពេញ ប្រធានគណកម្មាធិការ
2. លោកស្រី យស ធី KWWA ក្រចេះ អនុប្រធានគណកម្មាធិការ
3. លោកស្រី រស់ ធវីវណ្ណ VSG បាត់ដំបង សមាជិក
4. លោកស្រី ព្រំ បុប្ផា RAO ស្វាយរៀង សមាជិក
5. លោក ហ៊ឹម សារឿន SORF ពោធិ៍សាត់ សមាជិក



## ៦. បូកសរុបលទ្ធផលសម្រេចបាននៃកច្ចប្រជុំ

- កិច្ចសហការណ៍ សម្របសម្រួលរវាង CHF និង HRF កាន់តែប្រសើរឡើងលើការងារត្រៀមបង្ការ និងឆ្លើយតបគ្រោះអាសន្ន

- សមាជិក CHF បានដឹងពីលទ្ធផលសម្រេចបានរបស់វេទិកានាឆ្នាំកន្លងមក និងផែនការបន្តសម្រាប់គម្រោងថ្មី ២ឆ្នាំខាងមុខ
- និតិវិធីបទដ្ឋានប្រតិបត្តិ CHF សម្រាប់គណៈកម្មាធិការដឹកនាំវេទិកា អ្នកសម្របសម្រួល CHF ថ្នាក់តំបន់ និងថ្នាក់ខេត្ត ត្រូវបានកែសម្រួល ដោយមានការឯកភាពពីសមាជិក
- អ្នកសម្របសម្រួល CHF តំបន់ IV (ខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន) និងតំបន់ VII (ខេត្តតាកែវ កំពត និងកែប) ត្រូវបានជ្រើសរើស បន្ទាប់ពីអ្នកសម្របសម្រួល CHF តំបន់ចាស់សុំលាឈប់
- អ្នកសម្របសម្រួល CHF ខេត្តព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង ឧត្តរមានជ័យ និងកំពត ត្រូវបានជ្រើសរើស បន្ទាប់ពីអ្នកសម្របសម្រួល CHF ខេត្ត ទាំងនោះបានលាឈប់ ឬមិនទាន់មាន
- សមាជិកទាំងអស់បានដឹងពីចំនួនអង្គការសរុប និងថវិកាដែលបានបង់សមាជិកភាព មកលេខាធិការដ្ឋាន
- សមាជិកគណៈកម្មាធិការដឹកនាំវេទិកា CHF អាណត្តិទី៣ ត្រូវបានបោះឆ្នោត និងជ្រើសរើស។

## ៧. ផែនការសកម្មភាពសំខាន់ៗត្រូវអនុវត្តបន្ត

- ❖ រៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃគ្រោះអាសន្ន ចំនួន៥វគ្គ ចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០១៦ តទៅ ដែល១វគ្គមានចំនួន២៥នាក់។ សមាជិកទាំងអស់អាចចុះឈ្មោះចូលរៀនបានតាមរយៈគេហទំព័រ ឬផ្ញើឈ្មោះមកលេខាធិការដ្ឋានតាមរយៈ email
- ❖ រៀបចំសិក្ខាសាលាស្តីពី វិស័យទំនាក់ទំនង និងការប្រើប្រាស់គេហទំព័រ
- ❖ សហការណ៍ជាមួយ HRF រៀបចំផែនការត្រៀមបម្រុងយថាហេតុរួមគ្នារវាង CHF និង HRF និងរៀបចំកំណត់ថា តើអង្គការណាធ្វើអ្វី និងនៅកន្លែងណា (3ws)
- ❖ ផ្តល់វគ្គរំឭកឡើងវិញសម្រាប់ក្រុមវាយតម្លៃគ្រោះអាសន្ន
- ❖ បង្កើតបន្ថែមក្រុមអ្នកស្ម័គ្រចិត្តមូលដ្ឋានឆ្លើយតបគ្រោះអាសន្ន ២ក្រុម នៅ២ខេត្ត ព្រមទាំងផ្តល់នូវការបណ្តុះបណ្តាល និងការងារយុទ្ធនាការត្រៀមបង្ការទឹកជំនន់
- ❖ បន្តកិច្ចសហការណ៍ជាមួយ HRF និងភាគីពាក់ព័ន្ធស្តីពីការឆ្លើយតបគ្រោះមហន្តរាយ
- ❖ រៀបចំកិច្ចប្រជុំសម្របសម្រួលជាទៀងទាត់ជាមួយ គណៈកម្មាធិការដឹកនាំវេទិកា និងអ្នកសម្របសម្រួលថ្នាក់តំបន់
- ❖ រៀបចំសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីការរៀនសូត្រពីបទពិសោធន៍របស់ CHF ជាមួយសមាជិកទាំងអស់ និងភាគីពាក់ព័ន្ធ
- ❖ គាំទ្រសាកលវិទ្យាល័យភូមិន្ទភ្នំពេញ រៀបចំសិក្ខាសាលា២លើក